ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**
**សំណុំរឿងព្រហ្មទណ្ឌ**
**Criminal Case File /Dossier pénal**
**លេខ/No: 002/14-08-2006**
**លេខស៊ើបសួរ/Investigation/Instruction**
**លេខ/No: 002/19-09-2007-ECCC-OCIJ**

# ដីកាសម្រេចអំពីការបន្តថេរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន
# Order on Extension of Provisional Detention
# Ordonnance sur la prolongation de la détention provisoire

យើង **យូ ប៊ុនឡេង** និង **Marcel LEMONDE** (ម៉ាសែល ឡឺម៉ុង) សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤

បានឃើញវិធាន ៦៣(៧) នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ

បានឃើញការបើកការស៊ើបសួរលើឈ្មោះ **នួន ជា** និងជនផ្សេងទៀត
ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានធ្ងន់ធ្ងរលើសន្ធិសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៥ មាត្រា៦ មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

បានឃើញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០០៧

បានឃើញសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០០៨

បានឃើញសេចក្តីជូនដំណឹងចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ ២០០៨ ដែលក្នុងនោះយើងបានជូនដំណឹងដល់ជនត្រូវចោទ និងមេធាវីរបស់ខ្លួនអំពីគោលបំណងរបស់យើងក្នុងការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ដែលនឹងត្រូវផុតរលត់នៅថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០០៨ ហើយនិងបានឲ្យជាដំណឹងដល់ពួកគេថា ពួកគេមានរយៈពេល ១៥ ថ្ងៃ ដើម្បីធ្វើការកត់សម្គាល់ ឬតវ៉ាមកយើង

បានឃើញការតវ៉ាជំទាស់របស់ជនត្រូវចោទ ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ ២០០៨

យល់ឃើញថាការតវ៉ាជំទាស់របស់ជនត្រូវចោទពាក់ព័ន្ធជាសំខាន់នឹងល័ក្ខខ័ណ្ឌ ដែលមានកំណត់នៅក្នុងវិធាន ៦៣(៣)(ក) នៃវិធានផ្ទៃក្នុង។ តាមរយៈដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០០៧ សហចៅក្រមស៊ើបអង្កេតយល់ថា មានហេតុផលសមស្រប ដែលនាំឲ្យជឿថា នួន ជា បានប្រព្រឹត្តឧក្រិដ្ឋកម្មដូចដែលបានចោទប្រកាន់។ ក្នុងសេចក្តីសម្រេចរបស់ខ្លួន ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០០៨ ឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះយល់ថា ភ័ស្តុតាងដែលមាននៅក្នុងសំណុំរឿងក្នុងដំណាក់កាលនោះ (ជាពិសេសសូមមើល កថាខណ្ឌ ៤៣-៥៨) មានលក្ខណៈគ្រប់គ្រាន់ ដើម្បីបង្ហាញអំពីការជឿជាក់នេះ។ ក្រោយមក ការស៊ើបសួរលើជនត្រូវចោទក៏នៅតែបន្ត។ សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់លើភ័ស្តុតាងបន្ថែមនានាដែលប្រមូលបាន និងបានដាក់បញ្ចូលភ័ស្តុតាងទាំងនោះទៅក្នុងសំណុំរឿង ជាពិសេសរួមមានចម្លើយចំនួន ២៣ របស់ជនត្រូវចោទ កាំង ហ្គេកអ៊ាវ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ទាក់ទងទៅនឹងបរិបទ និងដំណើរការនៃមន្ទីរ ស-២១ ក៏ដូចជាតួនាទីរបស់ជនត្រូវចោទ នួន ជា នៅក្នុងបញ្ហាទាំងនោះផងដែរ។ ដូច្នេះសហចៅក្រមស៊ើបអង្កេតយល់ថាល័ក្ខខ័ណ្ឌ ដែលមានកំណត់នៅក្នុងវិធាន ៦៣(៣)(ក) នៃវិធានផ្ទៃក្នុង នៅតែត្រូវបានបំពេញ

យល់ឃើញថា លក្ខខណ្ឌនានាដែលមានកំណត់នៅក្នុងវិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុង ក៏នៅតែត្រូវបានបំពេញ ហើយថាសំអាងហេតុនៅក្នុងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០០៨ នៅតែមានសុពលភាពដដែល

## អាស្រ័យហេតុនេះ

សម្រេចឲ្យមានការបន្តថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ នួន ជា ក្នុងរយៈពេលអតិបរមាចំនួនមួយឆ្នាំបន្ថែមទៀត ដោយអនុលោមតាមបទប្បញ្ញត្តិនៃវិធាន ៦៣(៦)(ក) នៃវិធានផ្ទៃក្នុង។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០០៨

**សហចៅក្រមស៊ើបអង្កេត**

**Co-Investigating Judges**

**Co-juges d'instruction**


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.